# ទស្សនកិច្ចសិក្សារបស់យុវជនជនជាតិដើមភាគតិចរតនគីរី



ដើម្បីពង្រឹងសមត្ថភាពរបស់យុវជនជនជាតិដើមភាគតិចរតនៈគីរី លើសកម្មភាពទីផ្សារ និងការលក់រួមទិញរួមនៅក្នុងសហគមន៍ នៅថ្ងៃទី ១១ ដល់ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៨ គំរោងបណ្តាញទីផ្សារសហគមន៍ជនជាតិដើមភាគតិចបានរៀបចំទស្សនកិច្ចសិក្សាមួយទៅកាន់ខេត្តកំពង់ចាម ទីផ្សារក្នុងទីក្រុងភ្នំពេញ និងផ្សារណាត់ខេត្តតាកែវ ។ នៅក្នុងដំណើរការទស្សនកិច្ចនេះ មានយុវជនជាជនជាតិដើមភាគតិចចំនួន ១៦ នាក់ និងតំណាងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិរបស់អង្គការ ឌី-ភី-អេ ប្រចាំខេត្តរតនគីរី ចំនួន ២ នាក់។ ដំណើរទស្សនកិច្ចប្រព្រឹត្តិទៅក្រោមការឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលប្រទេសអេស្ប៉ាញ តាមរយៈមូលនិធិអ៊ីទៃ (ETEA Foundation)។ សរុបអ្នកចូលរួមទាំងអស់មានចំនួន ១៨ នាក់ (ស្ត្រី ៥ នាក់)។

ដំណើរការទស្សនកិច្ចសិក្សានេះធ្វើឡើងក្នុងគោលបំណង :

- ដកស្រង់បទពិសោធន៍ល្អៗទាក់ទងនឹងបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិ
- ដកស្រង់បទពិសោធន៍លើដំណើរផ្សារសហគមន៍ និងការគ្រប់គ្រង
- ច្រវាក់ទីផ្សាររបស់ផលិតផលនៅតាមសហគមន៍ និងនៅទីក្រុងភ្នំពេញ
- ដំណើរការ និងការគ្រប់គ្រងផ្សារកសិផលធម្មជាតិ និងភោជនីយដ្ឋានបក្សីស្រុក ។

ជាទូទៅក្រុមសិក្ខាកាមមានការសប្បាយរីករាយជាខ្លាំង ដោយពួកគេរៀនសូត្រនូវបទពិសោធន៍ជាច្រើនតាមរយៈការអង្កេតទស្សនាកសិដ្ឋាន និងទីផ្សា សាកសួរ និងការពន្យល់បង្ហាញពីកសិករ ។ ជាងនេះទៅទៀត ពួកគេបានមានឱកាសមកស្គាល់តំបន់ផ្សេងៗ ក្រៅពីខេត្តរបស់ខ្លួនដែលពីមុនមកពួកគេមិនដែលបានស្គាល់ទាល់តែសោះ។